# ចម្លាក់រាងរង្វង់ (Medallions) នៅស.វ.ទី៧

Medallion គឺជាពាក្យមួយដែលទំនងក្លាយចេញពីភាសាអ៊ីតាលីថា “Medaglioni” ឬមកពីភាសាបារាំងថា “Médaillons”។ ពាក្យនេះ គេច្រើនហៅសំដៅទៅលើប្រភេទចម្លាក់ដែលមានរង្វង់ ហើយជាទូទៅគេមិនអាចកំណត់និយមន័យយ៉ាងណាឱ្យប្រាកដនោះទេ។ នៅក្នុងបរិបទអារ្យធម៌បុរាណ ពាក្យនេះគេអាចហៅសំដៅដល់កាក់របស់ជនជាតិរ៉ូម៉ាំង ដ្បិតកាក់នោះមានរាងមូល ឬរាងជារង្វង់។ ទោះបីជាយ៉ាងណា អ្នកស្រាវជ្រាវភាគច្រើនបានកំណត់និយមន័យ Medallion ថា គឺជាប្រភេទចម្លាក់បុរាណរាងរង្វង់ធំៗ ដែលមានទំហំធំជាងកាក់របស់រ៉ូម៉ាំង។ ចម្លាក់ដែលមានរាងរង្វង់នៅសម័យបុរាណ គេអាចមើលឃើញតាមរយៈសិល្បៈជាច្រើន រាប់បញ្ចូលទាំងសិល្បៈនៅតំបន់អឺរ៉ុប អាស៊ីកណ្ដាល អាស៊ីខាងត្បូង និងព្រមទាំងមាននៅអាស៊ីអាគ្នេយ៍ថែមទៀតផង។ ជាឧទាហរណ៍ ចម្លាក់រាងរង្វង់នេះ បានលេចឡើងនៅក្នុងសិល្បៈខ្មែរនាស.វ.ទី៧ ជាពិសេស គឺគេឃើញមាននៅក្នុងសិល្បៈនៅតំបន់ប្រាសាទសំបូរព្រៃគុក (អតីតរាជធានីឦសានបុរៈ)។ នៅក្នុងអត្ថបទនេះ យើងនឹងសាកល្បងពិចារណាថា តើចម្លាក់រាងរង្វង់ ឬ Medallions ដែលឃើញមាននៅស.វ.ទី៧ នេះ មានប្រភពចេញមកពីណា? ហើយមានលក្ខណៈបែបណាខ្លះ?

នៅក្នុងសិល្បៈខ្មែរស.វ.ទី៧ ចម្លាក់រាងរង្វង់ ឬ Medallions សិល្បករច្រើនឆ្លាក់នៅលើផ្ដែរទ្វាររចនាបថសំបូរព្រៃគុក។ ចម្លាក់ទាំងនោះ ភាគច្រើនគេឆ្លាក់នៅលើក្បាច់បន្ទាត់ធ្នូដែលមានរាងកោង ហើយទំហំចម្លាក់រាងរង្វង់ទាំងនោះ តែងតែមានទំហំតូច ដោយមានឆ្លាក់រូបទេពជិះលើសត្វផ្សេងៗ ឬឆ្លាក់រូបភាពផ្សេងៗជាច្រើនទៀត។ ឧទាហរណ៍ ផ្ដែរទ្វារជាច្រើនដែលរកឃើញនៅតំបន់ប្រាសាទសំបូរព្រៃគុក គេច្រើនឃើញចម្លាក់នៅខាងក្នុងរង្វង់ គឺជាព្រះឥន្ទ្រគង់នៅលើសត្វដំរី និងអមដោយរូបទេពមកុតជិះនៅលើសេះ (រូបលេខ១-២)។ ចម្លាក់ព្រះឥន្ទ្រ អមដោយទេពមកុតនេះ គេយល់ថា ជារូបតំណាងឱ្យអំណាចរបស់ព្រះរាជា និងកងទ័ពរបស់ទ្រង់ ព្រោះតាមរយៈភស្តុតាងនៅស.វ.ទី៧ គេបានរៀបរាប់បង្ហាញថា ព្រះមហាក្សត្រ ដែលជាស្ដេចនៅស្ថានមនុស្ស គឺមានឫទ្ធានុភាពដូចព្រះឥន្ទ្រដែលជាស្ដេចនៅស្ថានសួគ៌។

ក្រៅពីចម្លាក់រាងរង្វង់នៅលើផ្ដែរទ្វារ នៅក្រុមប្រាសាទយាយព័ន្ធ (ក្រុមខាងត្បូង នៃតំបន់ប្រាសាទសំបូរព្រៃគុក) សិល្បករបុរាណបានឆ្លាក់ចម្លាក់រាងរង្វង់រួមជាមួយរូបភាពផ្សេងៗនៅខាងក្នុងនៅលើកំពែងខាងលិចរបស់ប្រាសាទ ដែលជាប្រភេទចម្លាក់រាងរង្វង់ឆ្លាក់នៅលើឥដ្ឋ។ ក្នុងនោះ យើងសង្កេតឃើញថា ចម្លាក់រាងរង្វង់ទាំងនោះ គេធ្វើឡើងក្នុងទំហំធំៗ ឱ្យមានភាពស៊ីគ្នាជាមួយទំហំនៃកំពែងរបស់ប្រាសាទ។ មិនត្រឹមប៉ុណ្ណោះ ចម្លាក់ទាំងនោះ គេឆ្លាក់នៅខាងក្រៅផង និងខាង

អត្ថបទដោយ៖ ម៉ង់ រ៉ាលី

ក្នុងផង ដែលចម្លាក់មួយចំនួនគេឃើញត្រឹមតែរង្វង់ប៉ុណ្ណោះ ដោយមិនទាន់មានចម្លាក់រូបផ្សេងៗនៅខាងក្នុងឡើយ (រូបលេខ២៣)។ សបញ្ជាក់ឱ្យឃើញថា ចម្លាក់រាងវង្វង់នៅកំពែងខាងលិចនៃក្រុមប្រាសាទយាយព័ន្ធនេះ ពុំទាន់សាងសង់ឡើងរួចរាល់នៅឡើយទេ។ ចម្លាក់ទាំងនោះទៀតសោតគេពិបាកនឹងកំណត់ថាជាសាច់រឿងអ្វីឱ្យប្រាកដឡើយ។ ក្នុងនោះ លោក ស៊ីយ៉ុន សុភារិទ្ធ បានកត់សម្គាល់ចម្លាក់មានរូបតួអង្គស្វាកំពុងថ្វាយអ្វីមួយដល់តួអង្គស្រី ថាជាឈុតមួយនៃរឿងរាមយណត្រង់ឈុតដែលហនុមានថ្វាយព្រះទម្រង់ទៅដល់ព្រះនាងសីតានៅក្រុងលង្កា (រូបលេខ២៤)។ ចម្លាក់មួយទៀតដែលមានរូបសត្វតោ អាចជាឈុតបង្ហាញពីព្រះនាងទុគ៌ា (មហេសីព្រះសិវ) ដ្បិតទ្រង់មានយានជំនិះជាសត្វតោ (រូបលេខ២៥)។ ក្រៅពីនេះ មានចម្លាក់មួយទៀតមានភាពរលុបច្រើន តែគេនៅអាចមើលឃើញរូបក្បាលសត្វក្របី ក៏អាចចាត់ទុកថារូបនោះជារូបព្រះនាងទុគ៌ាប្រយុទ្ធជាមួយបិសាចក្របី (ទុគ៌ាមហិស្សុរ) (រូបលេខ២៦)។

បញ្ហាដែលត្រូវលើកយកមកពិចារណានោះគឺថា តើចម្លាក់មេដាយ៉ុង (រាងវង្វង់) នេះ ទំនងមានប្រភពមកពីណា? ដើម្បីបកស្រាយចំណុចនេះ យើងគប្បីស្វែងយល់អំពីប្រភពដើមនៃចម្លាក់នេះជាមុនសិន។ ជាទូទៅ អ្នកស្រាវជ្រាវកំណត់ថាសិល្បៈមានរាងវង្វង់ ឬមេដាយ៉ុង ទំនងកើតចេញដំបូងគេនៅក្នុងសិល្បៈរ៉ូម៉ាំង ដ្បិតនៅជំនាន់ស្តេចអាឡិចហ្សង់កាន់កាប់ទឹកដី គេបានផលិតកាក់ជាច្រើនដែលមានរាងមូល ហើយបានសាយភាយទៅតំបន់ជាច្រើននៃពិភពលោក។ ឥទ្ធិពលនៃកាក់រាងមូល ទំនងបានក្លាយទៅជាសិល្បៈមួយបែបដ៏ពេញនិយមនៅតាមបណ្ដាប្រទេសដែលមានអារ្យធម៌ចាស់ៗជាច្រើន ជាពិសេស គឺអាស៊ីកណ្ដាល និងអាស៊ីខាងត្បូង។ ឧទាហរណ៍ នៅស្ថានីយ Tillya Tepe (សព្វថ្ងៃប្រទេសអាហ្គាន់នីស្ថាន) គេបានរកឃើញផ្នូរសពឥស្សរជនដែលមានកប់របស់របរជាច្រើនមកជាមួយសព ដែលក្នុងនោះមានខ្សែក្រវ៉ាត់មាសមួយមានចម្លាក់រាងវង្វង់ចំនួន ៩ (រូបលេខ២៧)។ គ្រប់ចម្លាក់រាងវង្វង់ទាំងអស់សុទ្ធសឹងមានចម្លាក់ទេពស្រីមួយអង្គគង់នៅលើសត្វតោ ដែលអ្នកស្រាវជ្រាវសន្និដ្ឋានថា ជាទេពស្រីនៅក្នុងជំនឿពែរ្សបុរាណមានព្រះនាមថា "ណាណា" (Nana) ហើយទេពស្រីនេះទៀតសោតគេតុបតែងសម្លៀកបំពាក់ដូចទៅនឹងទេពស្រីម្នាក់ឈ្មោះ "អាតេមីស" (Artemis) ក្នុងក្រុមទេព "Dionysos" នៃជំនឿក្រិចបុរាណ (រូបលេខ២៨)។ ដូច្នេះ វាអាចមានន័យថា បើទោះបីខ្សែក្រវ៉ាត់នេះរកឃើញនៅតំបន់ Tillya Tepe នៃប្រទេសអាហ្គាន់នីស្ថានក៏ដោយ ក៏ឥទ្ធិពលនៃចម្លាក់នេះគឺទទួលឥទ្ធិពលពីសិល្បៈពែរ្សបុរាណ ហើយលាយបញ្ចូលគ្នាជាមួយវប្បធម៌ Hellenistic នៃអារ្យធម៌ក្រិច-រ៉ូម៉ាំង។ យើងសង្កេតឃើញថា ចម្លាក់រាងវង្វង់នៅលើខ្សែក្រវ៉ាត់មាសដែលរកឃើញនៅស្ថានីយ Tillya Tepe បង្ហាញពីទេពស្រីនៅលើសត្វតោ

អត្ថបទដោយ៖ ម៉ង់ វ៉ាលី

ដូចចម្លាក់រាងវង្វង់នៅកំពែងខាងលិចក្រុមប្រាសាទយាយព័ន្ធ (សំបូរព្រៃគុក) ដែរ ដោយគ្រាន់តែខុសគ្នាត្រង់បរិបទជំនឿសាសនាប៉ុណ្ណោះ (មួយជាសិល្បៈនៃជំនឿពែរ្ស ឬក្រិចបុរាណ (ណាណា) និងមួយទៀតជាសិល្បៈព្រហ្មញ្ញសាសនា (ទុគ៌ា)។ បរិបទសាសនាខុសគ្នា តែឥទ្ធិពលសិល្បៈមានទំនាក់ទំនងគ្នាបែបនេះ មិនមានអ្វីចម្លែកឡើយ ឧទាហរណ៍ សិល្បៈព្រះពុទ្ធសាសនានៅតំបន់ Gandhara ជាច្រើន បានទទួលយកឥទ្ធិពលសិល្បៈក្រិច-រ៉ូម៉ាំង។

ការបកស្រាយជាហូរហែខាងលើនេះ គឺក្នុងបំណងមួយសន្និដ្ឋានថា ចម្លាក់រាងវង្វង់ ឬ Medallions ដែលគេឃើញមាននៅក្នុងសិល្បៈខ្មែរនាស.វ.ទី៧ ក៏ទំនងទទួលឥទ្ធិពលសិល្បៈក្រិច-រ៉ូម៉ាំង ដូចគ្នាដែរ ប៉ុន្តែវាមិនមែនទទួលដោយផ្ទាល់ទេ ពោល គឺទទួលដោយប្រយោលតាមរយៈការហូរចូលនៃអារ្យធម៌ឥណ្ឌាមកក្នុងសង្គមខ្មែរនាពេលនោះ។ ប្រភពដ៏សំខាន់មួយដែលអាចពន្យល់ពីកស្តុតាងនេះបានគឺសិលាចារឹកដែលរកឃើញនៅសំបូរព្រៃគុក K.438 និង K.604 ដែលរៀបរាប់អំពីព្រាហ្មណ៍ម្នាក់មកពីស្រុកឥណ្ឌាឈ្មោះ "ទុគ៌ស្វាមិ" បានចូលមករស់នៅ និងបម្រើការងារនៅក្នុងរាជការខ្មែរក្នុងរាជ្យស្តេចឦសានវរ្ម័នទី១ (គ.ស.៦១៦-៦៣៧)។ ព្រាហ្មណ៍ម្នាក់ បានទទួលការសព្វព្រះរាជហឫទ័យពីព្រះរាជា រហូតបានទទួលបានការតែងតាំងជាមន្ត្រីធំនៅក្នុងជួររាជការដែលមានគោរម្យងារថា "ម្រតាញ" និងបានរៀបអភិសេកជាមួយបុត្រីស្តេចឦសានវរ្ម័នថែមទៀតផង។ នៅក្នុងសិលាចារឹកខាងលើ ក៏បានផ្តល់ព័ត៌មានបន្ថែមថា "ម្រតាញទុគ៌ស្វាមិ" ជាព្រាហ្មណ៍មកពីស្រុកឥណ្ឌាពិតមែន ប៉ុន្តែព្រះអង្គម្ចាស់រូបនេះមានដើមកំណើតជាជនជាតិ "សក" (Śaka) ដែលស្ថិតនៅក្នុងប្រទេសពែរ្សបុរាណ នៃតំបន់អាស៊ីកណ្តាលផងដែរ។ ដូច្នោះហើយ ឥទ្ធិពលនៃចម្លាក់រាងវង្វង់នៅក្នុងសិល្បៈខ្មែរនាស.វ.ទី៧ ក៏ប្រហែលជាកើតឡើងតាមរយៈវត្តមាននៃការមកដល់នៃព្រាហ្មណ៍ជនជាតិសកនេះផងដែរ ដ្បិតព្រះអង្គម្ចាស់ទំនងជាបានស្គាល់លក្ខណៈសិល្បៈបែបនេះរួចមកហើយ មុននឹងមកដល់ស្រុកខ្មែរ។

ជារួមមក ឆ្លងតាមការបង្ហាញខាងលើ ចម្លាក់រាងវង្វង់ ឬ Medallions ទំនងជាឥទ្ធិពលសិល្បៈមួយប្រភេទដែលមានប្រភពដើមមកពីអារ្យធម៌ក្រិច-រ៉ូម៉ាំង សាយភាយទៅកាន់តំបន់ជាច្រើននៅអាស៊ីកណ្តាល និងអាស៊ីខាងត្បូង ហើយបន្តសាយភាយហូរចូលក្នុងសង្គមអាស៊ីអាគ្នេយ៍តាមរយៈវត្តមាននៃការមកដល់របស់ព្រាហ្មណ៍មកពីស្រុកឥណ្ឌា ដែលមានដើមកំណើតជាជនជាតិសក (ពែរ្ស)។ ឥទ្ធិពលនៃចម្លាក់រាងវង្វង់នេះទៀតសោត គឺមានវត្តមានតាមសំណង់ព្រះពុទ្ធសាសនាជាច្រើននៅស្រុកឥណ្ឌានាសម័យដំបូងៗ ដូចដែលលោកស្រី Bénisti ធ្លាប់បានសិក្សាហើយក៏វត្តមានជាចម្លាក់ជីឥដ្ឋរាងវង្វង់ជាច្រើនដែលគេរកឃើញនៅតំបន់ភាគខាងត្បូងប្រទេសមី

អត្ថបទដោយ៖ ម៉ង់ វ៉ាលី

យ៉ាន់ម៉ា (តំបន់ Kyontu)។ ទោះជាយ៉ាងណាក៏ដោយ ការសន្និដ្ឋាននេះនៅតែមានបញ្ហាមិនប្រាកដជាក់លាក់នៅឡើយ រង់ចាំមានការសិក្សាស្រាវជ្រាវលម្អិតនៅពេលក្រោយបន្ថែមទៀត៕

## បញ្ជីឯកសារយោង


Ben, W. 2018. *Seeing the 'Foreigner' In the Art of Early Southeast Asia c. 1000 BCE – c. 900 CE*, Thesis submitted for the degree of PhD, SOAS University of London.

Bénisti, M. 1952. 'Le Médaillion Lotiforme dans la Sculpture Indienne du IIIe siècle avant J.-C. au VIIIe siècle après J.-C.', in: *Recherches et documents d'art et d'archéologie,* Tome IV. Paris.

Boisselier, J. 1966. *Asie du Sud-Est, Tome 1: Le Cambodge*. Manuel d'Archéologie d'Extrême-Orient 1. Paris: Éditions A. et J. Picard et Cie.

Bursche, A. 2017. 'Medallions', in: *Faces of Power, Roman Gold Coins from the Victor A. Adda Collection,* Edited by Haim Gitler and Gil Gambash, The Israel Museum, Jerusalem, London.
Coedès, G. 1952. *Inscription du Cambodge*, Tome IV: Hanoi.

Finot, L. 1928. 'Nouvelle Inscriptions de Sambor', *Bulletin de l'École française d'Extrême-Orient*, 28/1: 43-46.

Marsden, A. 2021. 'Medallions of the Roman Empire – an introduction', in: *Historical Medal Journal,* No. 3.
Peterson, S. 2011-12. 'Parthian Aspects of Objects from Grave IV, Tillya Tepe, with Particular Reference to the Medallion Belt', *Revisions to analysis of coin evidence.*

Siyon Sophearith. 2006. 'The life of the Ramayana in ancient Cambodia: a study of the political, religious and ethical roles of an epic tale in real time (1)', *Udaya,* No. 7, Phnom Penh.


អត្ថបទដោយ៖ ម៉ង់ វ៉ាលី



រូបលេខ២១៖ ចម្លាក់រាងវង្វង់ឆ្លាក់នៅលើផ្តែរទ្វាររចនាបថសំបូរព្រៃគុក (ផ្តែរតួប៉ម N4)



រូបលេខ២២៖ ចម្លាក់រាងវង្វង់ឆ្លាក់នៅលើផ្តែរទ្វាររចនាបថសំបូរព្រៃគុក (ផ្តែរទ្វារមកពីវត្តបឹងខាងត្បូង)



រូបលេខ២៣៖ ចម្លាក់រាងវង្វង់ឆ្លាក់នៅលើកំពែងខាងលិចក្រុមប្រាសាទយាយព័ន្ធ (សំបូរព្រៃគុក)

អត្ថបទដោយ៖ ម៉ង់ វ៉ាលី



រូបលេខ២៨៖ ចម្លាក់រាងវង្វង់ឆ្លាក់នៅលើកំពែងខាងលិចក្រុមប្រាសាទយាយព័ន្ធ (ទំនងរឿងរាមាយណ)



រូបលេខ២៩៖ ចម្លាក់រាងវង្វង់ឆ្លាក់នៅលើកំពែងខាងលិចក្រុមប្រាសាទយាយព័ន្ធ (ប្រហែលជាទុគ៌ា)

អត្ថបទដោយ៖ ម៉ង់ វ៉ាលី



រូបលេខ៦៖ ចម្លាក់រាងវង្វង់ឆ្លាក់នៅលើកំពែងខាងលិចក្រុមប្រាសាទយាយព័ន្ធ (ប្រហែលជាទុគ៌ា)



រូបលេខ៧៖ ចម្លាក់រាងវង្វង់ឆ្លាក់នៅខ្សែក្រវ៉ាត់មាសរកឃើញនៅទីបញ្ចុះសព Tillya Tepe, អាហ្គានីស្ថាន សាងនៅស.វ.ទី១, (ប្រភពរូបថត៖ National Museum of Afghanistan, MK 04.40.384)

អត្ថបទដោយ៖ ម៉ង់ វ៉ាលី



រូបលេខ៨៖ លម្អិតចម្លាក់រាងវង្វង់ធ្លាក់នៅខ្សែក្រវ៉ាត់មាសរកឃើញនៅទីបញ្ចុះសព Tillya Tepe, អាហ្គាន់នីស្ថាន, ស.វ.ទី១ (ប្រភពរូបថត៖ National Museum of Afghanistan, MK 04.40.384)

AMS
អរិយធម៌ខ្មែរ
KHMER CIVILIZATION

អត្ថបទដោយ៖ ម៉ង់ វ៉ាលី